## ៣-សារាចរ

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៨

### សារាចរលេខ ០២ សរ

### ស្តីពីការបន្តនិរន្តរភាពរបស់រាជរដ្ឋាភិបាល

***

ដូចបានប្រកាសនៅក្នុងកិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី នៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៨ និងដើម្បីអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មាត្រា៧ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

យើង អ៊ឹង ហួត នាយករដ្ឋមន្ត្រីទី១ និង ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា សូមធ្វើការណែនាំចំពោះមន្ត្រីរាជការស៊ីវិលទាំងអស់គ្រប់ជាន់ថ្នាក់ ដូចតទៅ ៖

រាជរដ្ឋាភិបាលបច្ចុប្បន្ន ដែលត្រូវចេញពីតំណែងនេះ នៅតែដឹកនាំកិច្ចការងារប្រចាំថ្ងៃជាធម្មតារហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័ននៅរក្សាសិទ្ធិ និងអំណាចពេញលេញដដែល រហូតដល់មានរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការថ្មីចូល មកកាន់តំណែងជំនួស ។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន អនុរដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងខេត្ត-ក្រុង មេត្តាចាត់តាំងអោយអនុវត្តអោយបានសំរេចលទ្ធផលខ្ពស់ ។

ជ.រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

# III- ការងារបណ្តាក្រសួង

## ១-នីតិការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨

### ប្រកាសលេខ ៧៩៩ ប្រក.សហវ.ពដ

### ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ សម្រាប់ ឆ្នាំ ១៩៩៨

***

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៥ នស/រកត/១០៩៥/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៥ និងលេខ ជស/រកត/០៦៩៧/១៨៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្ដីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២៤-ក្រ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

-បានឃើញច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៧ ស្ដីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ

-យោងតាមការចាំបាច់ ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ ឆ្នាំ ១៩៩៨

**សំរេច**

ប្រការ ១ : ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ ១៩៩៨ ត្រូវចាប់ប្រមូលពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ នៅគ្រប់អង្គភាពពន្ធដារ តាមមាត្រា១៤ នៃច្បាប់ ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៨ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន២សន្លឹក តាមគំរូឯកភាព និង ត្រូវមានបង្កាន់ដៃបង់ពន្ធឆ្នាំ ១៩៩៧ ឬ សក្ខីបត្រភ្ជាប់មកជាមួយដើម្បីបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ១៩៩៧ រួចហើយ ។

មន្ត្រីពន្ធដារត្រូវផ្ដល់លិខិតបញ្ជាក់សម្រាប់ការចុះបញ្ជីដល់អ្នកដែលបានបង់ពន្ធឆ្នាំ ១៩៩៧ ។

ប្រការ ២ : ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទណាពុំមានសក្ខីបត្របញ្ជាក់ថា បានបង់ពន្ធ ឆ្នាំ ១៩៩៧ ទេនោះ ត្រូវអោយបង់ប្រាក់ពន្ធសម្រាប់ឆ្នាំ១៩៩៧ និង បង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹង ប្រាក់ពន្ធថែមទៀត ទើបអនុញ្ញាតអោយបង់ពន្ធសម្រាប់ឆ្នាំ ១៩៩៨ ។

ប្រការ ៣ : ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនីមួយៗ ក្រោយពេលបានបង់ពន្ធត្រឹមត្រូវរួចហើយ ត្រូវបានទទួលបង្កាន់ដៃទទួលប្រាក់ពន្ធមួយសន្លឹក និង ប័ណ្ណសំគាល់មួយសន្លឹក សម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូននិងយានជំនិះ ។

បង្កាន់ដៃទទួលប្រាក់ពន្ធត្រូវតែរក្សាទុកជាមួយយានយន្ត និង ត្រូវយកជាប់ជាមួយសម្រាប់ជូនភ្នាក់ងារពន្ធដារ សមត្ថកិច្ចត្រួតពិនិត្យ ។

ប្រការ ៤ : ផ្អែកតាមបញ្ញត្តិនៃមាត្រា១៥ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ ១៩៩៩ ពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ១៩៩៩ ដោយមិនគិតពីមធ្យោបាយដឹកជញ្ជូនរបស់រដ្ឋ ឬ របស់អង្គការ ត្រូវបានកំណត់ក្នុងតារាងឧបសម្ព័ន្ធទី១ និងទី២ ភ្ជាប់ជាមួយនឹងប្រកាសនេះ ។

ពន្ធនេះត្រូវបានលើកលែងចំពោះ

-រថយន្តសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យ

-មធ្យោបាយដឹកជញ្ជូន និង យានជំនិះ របស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិដែលប្រើសម្រាប់បំពេញភារកិច្ចការពារប្រទេស ការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម

-មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់ស្ថានទូត កុងស៊ុល អង្គការ ឬបុគ្គលដែលមានអភ័យឯកសិទ្ធិការទូត ឬ កុងស៊ុល ។

ប្រការ ៥ : សម្រាប់ឆ្នាំ១៩៩៩ នេះ ប័ណ្ណបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិង យានជំនិះគ្រប់ប្រភេទ មានរូបរាង និង លក្ខណៈដូចតទៅ :

១-ប័ណ្ណរាងចតុកោណ :

ប័ណ្ណនេះសម្រាប់រថយន្ត និង ត្រាក់ទ័រគ្រប់ប្រភេទ

នៅខាងលើបំផុតមានអក្សរ “ ព្រះរាជាណាចក្រកម្ពុជា ” ចំកណ្តាលប័ណ្ណមានលេខ “ ៩៩ ” និងមានអក្សរ “ ប័ណ្ណបង់ពន្ធរថយន្ត ” សរសេរព័ទ្ធជុំវិញលេខ ៩៩ ។ នៅខាងក្រោមលេខ ៩៩ មានលេខរៀងនៃប័ណ្ណ និង នៅខាងក្រោមបំផុតមានអក្សរ “ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ” ។

ប័ណ្ណរាងចតុកោណនេះ មានប្រាំពណ៌គឺ :

-ប័ណ្ណពណ៌ខៀវខ្ចី សម្រាប់ត្រាក់ទ័រដែលមានប្រាក់ពន្ធពី ៣០.០០០៛ ដល់ ៥០.០០០៛ ។

-ប័ណ្ណពណ៌ផ្កាឈូក សម្រាប់រថយន្តដែលមានប្រាក់ពន្ធពី ៦០.០០០៛ ដល់ ១៥០.០០០៛ ។

-ប័ណ្ណពណ៌លឿងទុំ សម្រាប់រថយន្តដែលមានប្រាក់ពន្ធពី ១៨០.០០០៛ ដល់ ២៥០.០០០៛ ។

-ប័ណ្ណពណ៌បៃតង សម្រាប់រថយន្តដែលមានប្រាក់ពន្ធ ៤៥០.០០០៛ ។

-ប័ណ្ណពណ៌លឿងខ្ចី សម្រាប់រថយន្តដែលមានប្រាក់ពន្ធ ៧៥០.០០០៛ ។

*ប័ណ្ណរាងចតុកោណនេះ ត្រូវបិទនៅកញ្ចក់ខាងមុខ ផ្នែកខាងឆ្វេង ជ្រុងខាងលើ (មើលពីមុខ) នៃរថយន្ត និងត្រាក់ទ័រ ។

**២-បណ្ណរាងត្រីកោណ :**

-បណ្ណនេះសម្រាប់ទោចក្រយានយន្ត និង ត្រីចក្រយានយន្ត ។

នៅខាងលើបំផុតមានអក្សរ “ ព្រះរាជាណាចក្រកម្ពុជា ” ចំកណ្តាលបណ្ណមានលេខ “ ៩៩ ” និងមានអក្សរ “ បណ្ណបង់ពន្ធយានយន្ត ” សរសេរពុះកាត់កណ្តាលលេខ ៩៩ ។ នៅខាងក្រោមលេខ ៩៩ មានលេខសំគាល់តាមសន្លឹកបណ្ណ និងនៅខាងក្រោមបំផុតមានអក្សរ “ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ” ។

បណ្ណរាងត្រីកោណនេះ មានបីពណ៌គឺ :

-បណ្ណពណ៌ខៀវខ្ចី សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ៧០សម³ ចុះក្រោមមានប្រាក់ពន្ធ ៣.០០០៛ ។

-បណ្ណពណ៌ផ្កាឈូក សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ៧០សម³ ទៅ ១២០សម³ មានប្រាក់ពន្ធ ៤.៥០០៛ ។

-បណ្ណពណ៌លឿងទុំ សម្រាប់ទោចក្រយានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២០សម³ ឡើងទៅ និងត្រីចក្រយានយន្តដឹកទំនិញ ឬអ្នកដំណើរ មានប្រាក់ពន្ធពី ៧.៥០០៛ ដល់ ១៥.០០០៛។

*បណ្ណរាងត្រីកោណនេះ ត្រូវបិទនៅចុងកំរបាំងមុខនៃទោចក្រយានយន្ត និង សម្រាប់ត្រីចក្រយានយន្ត ត្រូវបិទនៅខាងចុងផ្នែកខាងក្រោយនៃត្រីចក្រយានយន្ត ។

**៣-បណ្ណរាងមូល :**

បណ្ណនេះសម្រាប់ជលយាន ឬជលយានយន្តគ្រប់ប្រភេទ ។

នៅខាងលើបំផុតមានអក្សរ “ ព្រះរាជាណាចក្រកម្ពុជា ” ចំកណ្តាលបណ្ណមានលេខ “ ៩៩ ” និងមានអក្សរ “ បណ្ណបង់ពន្ធជលយាន ” សរសេរពុះកាត់ពាក់កណ្តាលលេខ ៩៩ ។ ខាងក្រោមលេខ ៩៩ មានលេខសំគាល់សន្លឹក បណ្ណ និង នៅខាងក្រោមបំផុតមានអក្សរ “ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ” ។

បណ្ណរាងមូលនេះ មានបីពណ៌គឺ :

-បណ្ណពណ៌ផ្កាឈូក សម្រាប់បិទលើជលយាន ឬ ជលយានយន្ត ដែលមានប្រាក់ពន្ធពី ១០.០០០៛ ដល់ ៦០.០០០៛ ។

-បណ្ណពណ៌លឿងទុំ សម្រាប់បិទលើជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធពី ១០០.០០០៛ ដល់ ៥០០.០០០៛ ។

-បណ្ណពណ៌ខៀវខ្ចី សម្រាប់បិទលើជលយាន ឬ ជលយានយន្ត ដែលមានប្រាក់ពន្ធពី ៦០០.០០០៛ ដល់ ១.២០០.០០០៛ ។

*បណ្ណរាងមូលនេះ ត្រូវបិទផ្ទៃខាងមុខនៃជលយាន ឬ ជលយានយន្ត ។

ប្រការ ៦ : ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៩ តទៅ អង្គភាពពន្ធដារនឹងធ្វើការត្រួតពិនិត្យដាក់ពិន័យចំនួន ស្មើពីរដងនៃប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះ ទាំងឡាយណាដែលមិនបានមកបង់ពន្ធសម្រាប់ឆ្នាំ ១៩៩៨ ដូចបានកំណត់ក្នុងប្រការ១ ខាងលើ ។

ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលទើបដាក់អោយធ្វើចរាចរនៅក្រោយថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៩ ត្រូវមានវិក្កយបត្រ ឬ ឯកសារផ្សេងៗចេញដោយអ្នកលក់ សម្រាប់បញ្ជាក់ ។

ប្រការ ៧ : ប្រាក់ពិន័យដែលទទួលបានមកពីការពិន័យលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ ដែលចែងនៅក្នុងប្រកាសនេះ ត្រូវបានអនុញ្ញាតអោយបែងចែកដូចតទៅ :

១-ប្រាក់ពិន័យដែលទទួលក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ ( លើផងផ្លូវសាធារណៈ ) ដែលមានសហការរវាងមន្ត្រីពន្ធដារ និង មន្ត្រីមានសមត្ថកិច្ចតម្រួតចរាចរ ត្រូវបានអនុញ្ញាតអោយដកចំនួន ៥០% លើប្រាក់ដែលពិន័យបានសម្រាប់រង្វាន់ ដោយត្រូវបែងចែក :

-៦០% នៃប្រាក់រង្វាន់ សម្រាប់ចែកជូនសមាជិកនៃក្រុមប្រតិបត្តិការត្រួតពិនិត្យ ក្នុងនោះមាន មន្ត្រីពន្ធដារ និង តម្រួតចរាចរ ។

-៤០% នៃប្រាក់រង្វាន់ សម្រាប់បង្កើតជាមូលនិធិរង្វាន់សរសើរ សម្រាប់នាយកដ្ឋានពន្ធដារ (២០%) សម្រាប់អង្គភាពអភិបាលខេត្ត ( ១០% ) និងសម្រាប់សាខាពន្ធដារខេត្ត - ក្រុង (១០%)។

២-ប្រាក់ពិន័យដែលទទួលបានក្រៅពីការត្រួតពិនិត្យ ( លើផងផ្លូវសាធារណៈ ) ដូចចែងក្នុងកថាខណ្ឌ ១ ខាងលើ ត្រូវអនុញ្ញាតអោយដក ១៥% នៃប្រាក់ពិន័យ សម្រាប់បង្កើតជាមូលនិធិរង្វាន់សរសើរ សម្រាប់នាយកដ្ឋានពន្ធដារ ( ៥% ) និងសម្រាប់សាខាពន្ធដារខេត្ត - ក្រុង ( ១០ % ) ។

៣-ប្រាក់ពិន័យដែលនៅសល់ពីការដករង្វាន់ត្រូវបង់ចូលថវិការដ្ឋ ។

ប្រការ ៨ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន**

★ ★ ★

## តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវបង់កំណត់
## ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
## ( តារាងឧបសម្ព័ន្ធទី១ )

★ ★ ★

ភ្ជាប់ជាមួយប្រកាសលេខ ៧៩៩ ប្រក.សហវ.ពដ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៨
របស់ក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | ចំនួនប្រាក់ពន្ធសំរាប់១ឆ្នាំក្នុងមួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញ : | | |
| + ដល់ ៣ តោន | ១៥០ ០០០ | |
| + លើសពី ៣ តោន ដល់ ១០ តោន | ២៥០ ០០០ | |
| + លើសពី ១០ តោន ដល់ ២០ តោន | ៥៥០ ០០០ | |
| + លើសពី ២០ តោន | ៧៥០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត-ក្រុង ធុនធំ មានកៅអីលើស ពី ៣០ កៅអី | ២៥០ ០០០ | |
| -រថយន្តដឹកអ្នកដំណើរឆ្លងកាត់ខេត្ត-ក្រុង ធុនមធ្យម មានកៅអីដល់ ៣០ កៅអី | ២០០ ០០០ | |
| -រថយន្តដឹកអ្នកដំណើរក្នុងក្រុង ធុនធំ មានកៅអីលើសពី ៣០ កៅអី | ២០០ ០០០ | |
| - រថយន្តដឹកអ្នកដំណើរក្នុងក្រុង ធុនមធ្យម មានកៅអីដល់ ៣០ កៅអី | ១៥០ ០០០ | |
| -រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + កម្លាំងដល់ ៩ សេស | ១០០ ០០០ | ៦០ ០០០ |
| + កម្លាំងលើសពី ៩ សេស ដល់ ១២ សេស | ១៥០ ០០០ | ១០០ ០០០ |
| + កម្លាំងលើសពី ១២ សេស ឡើងទៅ | ២៥០ ០០០ | ១៦០ ០០០ |
| - ត្រាក់ទ័រកម្លាំង ៥២ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៥០ ០០០ | |
| - ត្រាក់ទ័រកម្លាំង ៦៥ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៥០ ០០០ | |
| - ត្រាក់ទ័រកម្លាំង ៣៥ សេស និង គ្រឿងចក្រប្រហាក់ប្រហែល | ៣០ ០០០ | |
| - ទោចក្រយានយន្តទំហំពិស្តុងដល់ ៧០ សម$^3$ | ៣ ០០០ | |
| - ទោចក្រយានយន្តទំហំពិស្តុងលើសពី ៧០សម$^3$ ដល់១២៥ សម$^3$ | ៥ ៥០០ | |
| - ទោចក្រយានយន្តទំហំពិស្តុងលើសពី ១២៥ សម$^3$ ឡើងទៅ | ៧ ៥០០ | |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | ១៥ ០០០ | |
| <u>ជលយាន ឬ ជលយានយន្ត ផ្លូវទន្លេ</u> : | | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | ១០០ ០០០ | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រដល់៣០ម៉ែត្រ | ២០០ ០០០ | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | ៣០០ ០០ | |

| | |
|---|---|
| - កប៉ាល់សណ្តោងមានកំលាំងដល់ ៥០ សេះ | ២០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | ៣០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | ៥០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | ៦០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | ១៥០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ឡើងទៅ | ៣០០ ០០០ |
| - កាណូតនេសាទមានកំលាំងដល់ ៥០ សេះ | ១០ ០០០ |
| - កាណូតនេសាទមានកំលាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | ២០ ០០០ |
| - កាណូតនេសាទមានកំលាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | ៣០ ០០០ |
| - ទូកម៉ាស៊ីនកន្ទុយវែង “ ជើងម៉ូតូ ” | ១០ ០០០ |
| - អូប៉័រមានកំលាំងដល់ ២៥ សេះ | ១៥០ ០០០ |
| - អូប៉័រមានកំលាំងលើសពី ២៥ សេះ ដល់ ៥០ សេះ | ២០០ ០០០ |
| - អូប៉័រមានកំលាំងលើសពី ៥០ សេះ ដល់ ៨០ សេះ | ៣០០ ០០០ |
| - អូប៉័រមានកំលាំងលើសពី ៨០ សេះ ដល់ ២០០ សេះ | ៤០០ ០០០ |
| - អូប៉័រមានកំលាំងលើសពី ២០០ សេះ ឡើងទៅ | ៥០០ ០០០ |
| - **ជលយាន ឬ ជលយានយន្ត ផ្លូវសមុទ្រ :** | |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | ៣០០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | ៧៥០ ០០០ |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | ១ ២០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងដល់ ១៥០ សេះ | ៣០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | ៥០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | ៦០០ ០០០ |
| - កប៉ាល់នេសាទមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | ១ ២០០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងដល់ ២៥០ សេះ | ២០០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | ៤០០ ០០០ |
| - កប៉ាល់សណ្តោងមានកំលាំងលើសពី ៥០០ សេះ ឡើងទៅ | ៦០០ ០០០ |

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែតុលា ឆ្នាំ ១៩៩៨

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

គាត ឈន់

**តារាងឧបសម្ព័ន្ធកំណត់កំលាំងសេះរបស់រថយន្តទេសចរណ៍ ( តារាងឧបសម្ព័ន្ធទី២ )**
**ភ្ជាប់ជាមួយប្រកាសលេខ ៧៩៩ ប្រក.សហវ.៣ដ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៨**
**របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

★★★

| រថយន្តទេសចរណ៍ ដែលប្រើប្រាស់ឋាមពល | ចំនួន CC " វ៉ូលូម " | កំលាំងគិតជាសេះ | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ | |
| សាំង | ដល់ ១ ៥០០ cc | ដល់ ៩ សេះ | ១០០ ០០០ | ៨០ ០០០ | និយមហៅ ១.៥ |
| មាំហ្សូត | ដល់ ២ ២០០ cc | ដល់ ៩ សេះ | ១០០ ០០០ | ៨០ ០០០ | និយមហៅ ២.២ |
| សាំង | លើសពី ១ ៥០០ cc ដល់ ២ ០០០ cc | លើសពី ៩ សេះ ដល់ ១២ សេះ | ១៥០ ០០០ | ១០០ ០០០ | និយមហៅ ១.៦ ដល់ ២. |
| មាំហ្សូត | លើសពី ២ ២០០ cc ដល់ ៣ ០០០ cc | លើសពី ៩ សេះ ដល់ ១២ សេះ | ១៥០ ០០០ | ១០០ ០០០ | និយមហៅ ២.៥ ដល់ ៣. |
| សាំង | លើសពី ២ ០០០ cc ឡើងទៅ | លើសពី ១២ សេះ ឡើងទៅ | ២៥០ ០០០ | ១៨០ ០០០ | និយមហៅ ២.២ ដល់ឡើងទៅ |
| មាំហ្សូត | លើសពី ៣ ០០០ cc ឡើងទៅ | លើសពី ១២ សេះ ឡើងទៅ | ២៥០ ០០០ | ១៨០ ០០០ | និយមហៅ ៣.៨ ឡើងទៅ |

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែតុលា ឆ្នាំ ១៩៩៨
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
**គាត ឈន់**

****